# លក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណ និងប័ណ្ណនិម្មិតអេស៊ីលីដា
# Terms and Conditions of ACLEDA Card and Virtual Card

☆☆☆☆☆☆

## ១ លក្ខខណ្ឌរួម

លក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណ និងប័ណ្ណនិម្មិតអេស៊ីលីដា ឬហៅថា "លក្ខខណ្ឌប្រើប្រាស់ប័ណ្ណ" គឺជាកិច្ចសន្យា ឬកិច្ចព្រមព្រៀង រវាង ធនាគារ អេស៊ីលីដា ភីអិលស៊ី និងអតិថិជន ក្នុងការប្រើប្រាស់ប័ណ្ណអេស៊ីលីដា រួមទាំងប័ណ្ណនិម្មិតផងដែរ។ លក្ខខណ្ឌនេះ បង្កើតឡើង សម្រាប់ប្រើអមជាមួយ "ប័ណ្ណផ្សព្វផ្សាយ" និង "តារាងថ្លៃសេវាប័ណ្ណអេស៊ីលីដា"។

នៅពេលលោក-លោកស្រី យល់ព្រមលើការប្រើប្រាស់ប័ណ្ណអេស៊ីលីដា បញ្ជាក់ថាលោក-លោកស្រីត្រូវបានពន្យល់ និងណែនាំ ឬអានដោយខ្លួនឯង បានយល់ច្បាស់ និងព្រមព្រៀងនូវគ្រប់លក្ខខណ្ឌទាំងអស់ដែលបានចែងនេះ ហើយយល់ព្រមទទួលខុសត្រូវទាំងស្រុងលើប្រតិបត្តិការ ធនាគារ តាមរយៈការប្រើប្រាស់ប័ណ្ណរបស់លោក-លោកស្រី និងព្រមព្រៀងនូវលក្ខខណ្ឌផ្សេងទៀត ដូចជា ថ្លៃសេវា ការកំណត់ប្រតិបត្តិការ នៃការប្រើប្រាស់ប័ណ្ណ ដែលធនាគារ អេស៊ីលីដា ភីអិលស៊ី បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ហើយកិច្ចព្រមព្រៀងនេះនឹងត្រូវបានចូលជាធរមាន។

ធនាគារ អេស៊ីលីដា ភីអិលស៊ី អាចធ្វើការកែប្រែលក្ខខណ្ឌ និងថ្លៃសេវាប័ណ្ណ នៅពេលណាមួយ ដោយអនុលោមតាមច្បាប់ជាធរមាន និង/ឬស្ថានភាពជាក់ស្តែង។ ធនាគារ អេស៊ីលីដា ភីអិលស៊ី នឹងធ្វើការជូនដំណឹងនូវរាល់ការកែប្រែទាំងឡាយណាដែលប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់លោក-លោកស្រី (តាមមធ្យោបាយសមស្របណាមួយ ឬតាមលទ្ធភាពដែលធនាគារអាចធ្វើទៅបាន)។

នៅក្នុងលក្ខខណ្ឌនេះ ពាក្យថា "លោក-លោកស្រី" "របស់លោក-លោកស្រី" សំដៅដល់អតិថិជន ម្ចាស់ប័ណ្ណ ឬអ្នកប្រើប្រាស់ប័ណ្ណគ្រប់ប្រភេទ។ ពាក្យថា "យើង" "របស់យើង" និង "ធនាគារ" សំដៅដល់ធនាគារ អេស៊ីលីដា ភីអិលស៊ី។

## ២ ប័ណ្ណអេស៊ីលីដា ប្រភេទផ្លាស្ទិក

២.១ ប្រភេទប័ណ្ណ និងការប្រើប្រាស់ប័ណ្ណ ឬកាតផ្លាស្ទិក

២.១.១ ប័ណ្ណឥណពន្ធអេស៊ីលីដា រួមមាន៖

- ប័ណ្ណឥណពន្ធអេស៊ីលីដាធម្មតា និងប័ណ្ណឥណពន្ធអេស៊ីលីដាមាស : អាចធ្វើប្រតិបត្តិការដកប្រាក់, ដាក់ប្រាក់, ផ្ទេរប្រាក់, បញ្ចូលលុយទូរសព្ទ, ទូទាត់ប័ណ្ណឥណទានអេស៊ីលីដា តាមម៉ាស៊ីនអេធីអឹមអេស៊ីលីដា (ATM/CRM), ទូទាត់ថ្លៃទំនិញ-សេវាកម្ម តាមម៉ាស៊ីនឆូតកាតអេស៊ីលីដា ឬប្រព័ន្ធអ៊ីខុមមើសអេស៊ីលីដា (ACLEDA POS/E-Commerce), ដកប្រាក់នៅបញ្ជរធនាគារ តាមម៉ាស៊ីនឆូតកាតអេស៊ីលីដា និងដាក់ប្រាក់បញ្ញើមានកាលកំណត់តាមម៉ាស៊ីន TDM។
- អាយប៉ែង (i-bank PayBand) : អាចធ្វើប្រតិបត្តិការដកប្រាក់, ដាក់ប្រាក់, ផ្ទេរប្រាក់, បញ្ចូលលុយទូរសព្ទ, ទូទាត់ប័ណ្ណឥណទានអេស៊ីលីដា តាមម៉ាស៊ីនអេធីអឹមអេស៊ីលីដា (ATM/CRM) ដែលមានបំពាក់ប្រព័ន្ធ Contactless និងទូទាត់ចំណាយផ្សេងៗ តាមម៉ាស៊ីនឆូតកាតអេស៊ីលីដា (POS) ដែលមានបំពាក់ប្រព័ន្ធ Contactless។
- ប័ណ្ណឥណពន្ធទូទាត់រួមស្លាកសញ្ញា (Co-brand Card) : អាចធ្វើប្រតិបត្តិការដូច "ប័ណ្ណឥណពន្ធអេស៊ីលីដាធម្មតា"។
- ប័ណ្ណឥណពន្ធអន្តរជាតិ រួមមាន ប័ណ្ណឥណពន្ធវីសាអេស៊ីលីដា, ប័ណ្ណឥណពន្ធម៉ាស្ទ័រកាតអេស៊ីលីដា, ប័ណ្ណឥណពន្ធចេស៊ីប៊ីអេស៊ីលីដា និងប័ណ្ណឥណពន្ធយូភីអាយអេស៊ីលីដា ហើយអាចធ្វើប្រតិបត្តិការដូចខាងក្រោម៖
  - ដកប្រាក់, ដាក់ប្រាក់, ផ្ទេរប្រាក់, បញ្ចូលលុយទូរសព្ទ, ទូទាត់ប័ណ្ណឥណទានអេស៊ីលីដា តាមម៉ាស៊ីនអេធីអឹមអេស៊ីលីដា (ATM/CRM),
  - ដកប្រាក់តាមម៉ាស៊ីនអេធីអឹមអេស៊ីលីដា ឡារ ឬម៉ាស៊ីនអេធីអឹម ធនាគារផ្សេង (ទាំងក្នុង និងក្រៅប្រទេស),
  - ដកប្រាក់នៅបញ្ជរធនាគារ អេស៊ីលីដា និងបញ្ជរធនាគារផ្សេង (ទាំងក្នុង និងក្រៅប្រទេស) តាមម៉ាស៊ីនឆូតកាត (POS),
  - ទូទាត់ថ្លៃទំនិញ-សេវាកម្ម តាមម៉ាស៊ីនឆូតកាត ឬប្រព័ន្ធអ៊ីខុមមើស (POS/E-Commerce) របស់ធនាគារពាណិជ្ជទាំងអស់ នៅទូទាំងពិភពលោកដែលមានស្លាកសញ្ញាវីសា ម៉ាស្ទ័រកាត ចេស៊ីប៊ី និងយូភីអាយ,
  - ផ្ទេរប្រាក់ចេញពីប័ណ្ណឥណពន្ធវីសា/ម៉ាស្ទ័រកាតអេស៊ីលីដា ទៅប័ណ្ណឥណពន្ធ-ឥណទានវីសា/ម៉ាស្ទ័រកាតរបស់ធនាគារផ្សេង (ទាំងក្នុង និងក្រៅប្រទេស) តាមម៉ាស៊ីនអេធីអឹមអេស៊ីលីដា ឬតាមអេស៊ីលីដាម៉ូបាលស៊ូភើអេប,
  - ទទួលប្រាក់ផ្ទេរចូលពីអតិថិជនផ្សេង (ទាំងក្នុង និងក្រៅប្រទេស) និង
  - ស្នើសុំបោះពុម្ពប័ណ្ណ, បង្ខាំងប័ណ្ណ, ដោះបង្ខាំងប័ណ្ណ, កែប្រែទំហំទឹកប្រាក់ដកប្រចាំថ្ងៃ, កែប្រែទំហំទឹកប្រាក់ទូទាត់ប្រចាំថ្ងៃ, កែប្រែចំនួនប្រតិបត្តិការប្រចាំថ្ងៃ, ពិនិត្យមើលប្រវត្តិប្រតិបត្តិការប័ណ្ណ, ពិនិត្យមើលប្រវត្តិប្រតិបត្តិការគណនីសង្ខេប និងបិទប័ណ្ណ តាមអេស៊ីលីដាម៉ូបាលស៊ូភើអេប។

២.១.២ ប័ណ្ណឥណទានអេស៊ីលីដា រួមមាន ប័ណ្ណឥណទានវីសាអេស៊ីលីដា ប័ណ្ណឥណទានម៉ាស្ទ័រកាតអេស៊ីលីដា និងអាចធ្វើប្រតិបត្តិការដូចខាងក្រោម៖

- ដកប្រាក់, ដាក់ប្រាក់, បញ្ចូលលុយទូរសព្ទ, ទូទាត់ប័ណ្ណឥណទានអេស៊ីលីដា តាមម៉ាស៊ីនអេធីអឹមអេស៊ីលីដា (ATM/CRM),
- ដកប្រាក់ តាមម៉ាស៊ីនអេធីអឹមធនាគារផ្សេង (ទាំងក្នុង និងក្រៅប្រទេស), ដកប្រាក់នៅបញ្ជរធនាគារ អេស៊ីលីដា និងបញ្ជរធនាគារផ្សេង (ទាំងក្នុង និងក្រៅប្រទេស) តាមម៉ាស៊ីនឆូតកាត (POS),
- ទទួលប្រាក់ទូទាត់សំណងឥណទានអេស៊ីលីដា និងបញ្ចូលលុយទូរសព្ទតាមអេស៊ីលីដាម៉ូបាលស៊ូភើអេប,

- ទូទាត់ថ្លៃទំនិញ-សេវាកម្ម តាមអេស៊ីលីដាម៉ូបាលស្ទ័រអេប ដោយស្កេនឃ្យូអរកូដ ឬម៉ាស៊ីនឆូតកាត ឬប្រព័ន្ធអ៊ីខុមមើស (POS/E-Commerce) របស់ធនាគារពាណិជ្ជទាំងអស់នៅទូទាំងពិភពលោកដែលមានស្លាកសញ្ញាវីសា និងម៉ាស្ទ័រកាត,
- ផ្ទេរប្រាក់ទៅប័ណ្ណឥណពន្ធ-ឥណទានវីសា/ម៉ាស្ទ័រកាតរបស់ធនាគារផ្សេង (ទាំងក្នុង និងក្រៅប្រទេស) តាមម៉ាស៊ីនអេធីអឹមអេស៊ីលីដា ឬតាមអេស៊ីលីដាម៉ូបាលស្ទ័រអេប,
- ទទួលប្រាក់ផ្ទេរចូលពីអតិថិជនផ្សេង (ទាំងក្នុង និងក្រៅប្រទេស) និង
- បង្កាំងប័ណ្ណ, ដោះបង្កាំងប័ណ្ណ, កែប្រែទំហំទឹកប្រាក់ដកប្រចាំថ្ងៃ, កែប្រែទំហំទឹកប្រាក់ទូទាត់ប្រចាំថ្ងៃ, កែប្រែចំនួនប្រតិបត្តិការប្រចាំថ្ងៃ, ពិនិត្យមើលប្រវត្តិប្រតិបត្តិការប័ណ្ណ និងគណនីសង្ខេប តាមអេស៊ីលីដាម៉ូបាលស្ទ័រអេប។

២.១.៣ ប័ណ្ណឥណទានប្រើប្រាស់ផ្ទាល់ខ្លួន: អាចធ្វើប្រតិបត្តិការដូច "ប័ណ្ណឥណពន្ធអេស៊ីលីដាធម្មតា និងប័ណ្ណឥណពន្ធអេស៊ីលីដាមាស" ដែលមានចែងក្នុងចំណុច ២.១.១ ខាងលើ។

២.២ លក្ខខណ្ឌសម្រាប់អតិថិជនដើម្បីទទួលបានប័ណ្ណ ឬកាតផ្លាស្ទិក

២.២.១ ប័ណ្ណឥណពន្ធអេស៊ីលីដា

ប័ណ្ណឥណពន្ធអេស៊ីលីដាដែលផ្តល់ជូនអតិថិជនមានប័ណ្ណដើម និងប័ណ្ណបន្ទាប់។ លោក-លោកស្រី ជាម្ចាស់ប័ណ្ណដើម អាចស្នើសុំប័ណ្ណបន្ទាប់ទៅសម្ព័ន្ធញាតិ ដែលជាអនីតិជនមានអាយុក្រោម ១៨ឆ្នាំ តាមតម្រូវការប្រើប្រាស់ជាក់ស្តែង។

- ដើម្បីទទួលបានប័ណ្ណដើម លោក-លោកស្រី ជាជនជាតិខ្មែរ ឬបរទេសដែលជានីតិជនមានអាយុចាប់ពី ១៨ឆ្នាំ ត្រូវអនុវត្តដូចខាងក្រោម៖
  - ត្រូវមានគណនីប្រភពនៅធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលអាចជាគណនីបញ្ញើសំចៃ ឬគណនីចរន្ត ឬគណនីបញ្ញើតាមតម្រូវការ។
  - ត្រូវគោរពតាមគោលការណ៍ និងលក្ខខណ្ឌកំណត់ផ្សេងៗ របស់ធនាគារជាធរមាន។
  - ត្រូវស្នើសុំប័ណ្ណឥណពន្ធនៅតាមការិយាល័យ ឬតាមអេស៊ីលីដាម៉ូបាលស្ទ័រអេប។
- ដើម្បីទទួលបានប័ណ្ណបន្ទាប់ លោក-លោកស្រី (ជានីតិជន) ត្រូវផ្តល់មកធនាគារ និងបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖
  - ឯកសារដែលបញ្ជាក់ពីចំណងសម្ព័ន្ធញាតិរវាងម្ចាស់ប័ណ្ណដើម និងម្ចាស់ប័ណ្ណបន្ទាប់។
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លិខិតឆ្លងដែន សំបុត្រកំណើត ឬឯកសារសម្គាល់អត្តសញ្ញាណផ្សេងៗទៀតដែលមានសុពលភាព។
  - បំពេញទម្រង់ប្រើប្រាស់សេវាអេស៊ីលីដាឌីជីថល និងឯកសារសុពលភាពផ្សេងៗ តម្រូវដោយធនាគារ។
- ចំពោះប័ណ្ណឥណពន្ធទូទាត់រួមស្លាកសញ្ញា លោក-លោកស្រីអាចស្នើសុំតាមរយៈក្រុមហ៊ុន/ស្ថាប័ន ក្រសួង មន្ទីរ អង្គភាពសាមី ដោយមានឯកសារគាំទ្រ និងព័ត៌មានបន្ថែមផ្សេងទៀតតាមការកំណត់របស់អង្គភាពសាមី។

២.២.២ ប័ណ្ណឥណទានអេស៊ីលីដា

ប័ណ្ណឥណទានអេស៊ីលីដាដែលផ្តល់ជូនអតិថិជនមានប័ណ្ណដើម និងប័ណ្ណបន្ទាប់។ ចំពោះប័ណ្ណបន្ទាប់ត្រូវបានផ្តល់ជូនទៅតាមការស្នើសុំរបស់ម្ចាស់ប័ណ្ណដើម ទៅតាមតម្រូវការប្រើប្រាស់ជាក់ស្តែង ដោយអនុលោមតាមលក្ខខណ្ឌកំណត់របស់ធនាគារ។ ប័ណ្ណឥណទានអេស៊ីលីដា ត្រូវបានផ្តល់ជូនអតិថិជន ដូចខាងក្រោម៖

- ឯកត្តជន:
  - លោក-លោកស្រី ជានីតិជនមានអាយុចាប់ពី ១៨ឆ្នាំ ហើយចំពោះប័ណ្ណបន្ទាប់មានអាយុចាប់ពី ១៥ឆ្នាំ។
  - ត្រូវមានឯកសារអត្តសញ្ញាណដែលនៅមានសុពលភាព ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
  - ត្រូវមានគណនីធនាគារ ដើម្បីទូទាត់ប្រាក់សំណង និងត្រួតពិនិត្យប្រតិបត្តិការនៅក្នុងគណនី។
  - គោរព និងអនុលោមតាមលក្ខខណ្ឌឥណទាន និងទទួលបានការអនុម័តផ្តល់ឥណទានរួចរាល់ពីធនាគារ។
- ក្រុមហ៊ុន:
  - ត្រូវធ្វើការចាត់តាំង ឬផ្តល់សិទ្ធិ ជាលាយលក្ខណ៍អក្សរដល់អ្នកតំណាងជានីតិជន អាយុចាប់ពី ១៨ឆ្នាំ ដើម្បីឱ្យប្រើប្រាស់ប័ណ្ណឥណទាន។
  - ត្រូវមានឯកសារសម្គាល់អត្តសញ្ញាណដែលនៅមានសុពលភាពរបស់អ្នកមានសិទ្ធិ និងអ្នកតំណាង របស់ក្រុមហ៊ុន/ស្ថាប័ន។
  - ត្រូវផ្តល់ឯកសារក្រុមហ៊ុន/ស្ថាប័ន ដូចជា៖ លក្ខន្តិកៈ អនុស្សរណៈ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម លិខិតអនុញ្ញាតឱ្យដំណើរការក្រុមហ៊ុន/ស្ថាប័ន និងឯកសារផ្សេងទៀតដែលមានសុពលភាព។
  - ត្រូវមានគណនីធនាគារ ដើម្បីទូទាត់ប្រាក់សំណង និងត្រួតពិនិត្យប្រតិបត្តិការនៅក្នុងគណនី។
  - គោរព និងអនុលោមតាមលក្ខខណ្ឌឥណទាន និងទទួលបានការអនុម័តផ្តល់ឥណទានរួចរាល់ពីធនាគារ។

២.២.៣ ប័ណ្ណឥណទានប្រើប្រាស់ផ្ទាល់ខ្លួន

ប័ណ្ណឥណទានប្រើប្រាស់ផ្ទាល់ខ្លួនត្រូវបានផ្តល់ជូនអតិថិជន ដូចខាងក្រោម៖

- ជានីតិជនដែលមានអាយុចាប់ពី ១៨ឆ្នាំ។
- ត្រូវមានឯកសារអត្តសញ្ញាណដែលនៅមានសុពលភាព ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
- ត្រូវមានគណនីធនាគារ ដើម្បីទូទាត់ប្រាក់សំណង និងត្រួតពិនិត្យប្រតិបត្តិការនៅក្នុងគណនី។
- គោរព និងអនុលោមតាមលក្ខខណ្ឌឥណទាន និងទទួលបានការអនុម័តផ្តល់កម្រិតបន្ទាត់ឥណទានវិបារូបន៍រួចរាល់ពីធនាគារ។

## ៣ ប័ណ្ណនិម្មិតអេស៊ីលីដា

៣.១ ប័ណ្ណនិម្មិតអេស៊ីលីដា សំដៅដល់ព័ត៌មានប័ណ្ណឌីជីថល របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលបានបង្កើតតាមអេស៊ីលីដាម៉ូបាលស្ទ័រអេប សម្រាប់ប្រើប្រាស់ក្នុងការទូទាត់ថ្លៃទំនិញ-សេវាកម្ម តាមប្រព័ន្ធអនឡាញ (Online Shopping) ប្រកបដោយសុវត្ថិភាព។

៣.២ ប្រភេទប័ណ្ណនិម្មិតអេស៊ីលីដា មានដូចជា៖
- ប័ណ្ណនិម្មិតអេស៊ីលីដាវីសា
- ប័ណ្ណនិម្មិតអេស៊ីលីដាម៉ាស្ទ័រកាត
- ប័ណ្ណនិម្មិតអេស៊ីលីដាចេស៊ីប៊ី
- ប័ណ្ណនិម្មិតអេស៊ីលីដាយូភីអាយ

៣.៣ ប័ណ្ណនិម្មិតអេស៊ីលីដា អាចបង្កើតជារូបិយប័ណ្ណដុល្លារអាមេរិក ឬប្រាក់រៀល តាមគណនីឯកត្តជន និងគណនីរួម ដែលបានភ្ជាប់ជាមួយអេស៊ីលីដាម៉ូបាលស៊ូភើអេប, និងមាន ឬមិនមានប្រើប្រាស់ប័ណ្ណឥណពន្ធអេស៊ីលីដា។

៣.៤ ប្រភេទរូបិយប័ណ្ណ : ប័ណ្ណនិម្មិតអេស៊ីលីដា ប្រភេទវីសា, ម៉ាស្ទ័រកាត និងយូភីអាយ មានរូបិយប័ណ្ណជាប្រាក់ដុល្លារអាមេរិក។ ចំពោះប័ណ្ណនិម្មិតអេស៊ីលីដាចេស៊ីប៊ី មានរូបិយប័ណ្ណជាប្រាក់ដុល្លារអាមេរិក និងប្រាក់រៀល។ ក្នុងករណីអតិថិជនទូទាត់ជារូបិយប័ណ្ណផ្សេង ប្រព័ន្ធនឹងធ្វើការប្តូរប្រាក់ទៅតាមអត្រាប្តូរប្រាក់ផ្លូវការរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (VISA, MasterCard, JCB, UPI) នៅពេលទូទាត់នោះ។

៣.៥ សុពលភាពប័ណ្ណ : ប័ណ្ណនិម្មិតអេស៊ីលីដានីមួយៗ មានសុពលភាពរយៈពេល ០៣ឆ្នាំ ដោយគិតចាប់ពីថ្ងៃបង្កើត។ សម្រាប់ប័ណ្ណផុតសុពលភាព ព័ត៌មានរបស់ប័ណ្ណនឹងត្រូវបង្ខាំងមិនឱ្យប្រើប្រាស់បាន ហើយត្រូវដកចេញពីអេស៊ីលីដាម៉ូបាលស៊ូភើអេប។ ក្នុងករណីលោក-លោកស្រីមានបំណងប្រើប្រាស់ប័ណ្ណបន្ត ត្រូវបង្កើតប័ណ្ណថ្មីមួយផ្សេងទៀត។

៣.៦ នៅពេលបញ្ចូលព័ត៌មានត្រឹមត្រូវក្នុងពេលបង្កើតប័ណ្ណនិម្មិត ប្រព័ន្ធនឹងបង្កើតលេខប័ណ្ណចំនួន ១៦ខ្ទង់ (Card Number) ថ្ងៃខែឆ្នាំផុតកំណត់ (Expiry Date) លេខកូដបីខ្ទង់ (CVV2/CSV) និងចំនួនទឹកប្រាក់កំណត់ប្រចាំថ្ងៃ (Amount)។

៣.៧ ប័ណ្ណនិម្មិតនេះ អាចប្រើក្នុងការទិញ និងទូទាត់ថ្លៃទំនិញ-សេវាកម្ម ក្នុងប្រព័ន្ធ Internet/Online Shopping តាមសេវា E-Commerce ទាំងក្នុងប្រទេស និងក្រៅប្រទេស ពាសពេញពិភពលោក។ ចំពោះការធ្វើប្រតិបត្តិការតាមម៉ាស៊ីនអេធីអឹម (ATM/CRM) និងម៉ាស៊ីនឆូតកាត (POS) មិនត្រូវបានអនុញ្ញាតឡើយ។

៣.៨ លោក-លោកស្រីត្រូវតែបម្រុងសមតុល្យគណនីឱ្យបានគ្រប់គ្រាន់ ឬលើស រាល់ពេលបង្កើតប័ណ្ណ និងពេលទូទាត់ថ្លៃទំនិញ-សេវាកម្ម។ ប័ណ្ណនិម្មិតអេស៊ីលីដាដែលបានបង្កើត គឺមិនទាន់បានកាត់សមតុល្យចេញពីគណនីដើមភ្លាមនោះទេ។ សមតុល្យទឹកប្រាក់ក្នុងប័ណ្ណនិម្មិតអេស៊ីលីដានឹងត្រូវកាត់ចេញពីគណនីបញ្ញើសន្សំ ក្នុងករណីលោក-លោកស្រីយកប័ណ្ណនិម្មិតអេស៊ីលីដាទៅធ្វើប្រតិបត្តិការបញ្ជាទិញទំនិញ-សេវាកម្ម តាមប្រព័ន្ធអ៊ីនធឺណិត។

៣.៩ លោក-លោកស្រី អាចធ្វើការកែប្រែចំនួនទឹកប្រាក់កំណត់ប្រចាំថ្ងៃនៃប័ណ្ណនិម្មិតដែលបានបង្កើតរួច មកចំនួនទឹកប្រាក់កំណត់ថ្មី ឬកំណត់ចំនួនប្រតិបត្តិការប្រចាំថ្ងៃ សម្រាប់ធ្វើការទូទាត់បានតាមតម្រូវការ និងត្រួតពិនិត្យមើលប្រតិបត្តិការប័ណ្ណប្រចាំថ្ងៃ តាមអេស៊ីលីដាម៉ូបាលស៊ូភើអេប។

៣.១០ លោក-លោកស្រីអាចធ្វើការបង្ខាំង ឬដោះបង្ខាំងប័ណ្ណនិម្មិតអេស៊ីលីដា តាមអេស៊ីលីដាម៉ូបាលស៊ូភើអេប ឬទំនាក់ទំនងមកការិយាល័យទំនាក់ទំនងអតិថិជន ឬនៅតាមការិយាល័យធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលនៅជិតបំផុត។

៣.១១ លោក-លោកស្រី អាចបិទ ឬមោឃភាពប័ណ្ណនិម្មិតអេស៊ីលីដាណាដែលមិនមានតម្រូវការប្រើប្រាស់ តាមអេស៊ីលីដាម៉ូបាលស៊ូភើអេបឬមកកាន់ការិយាល័យធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលនៅជិតបំផុត។

## ៤ ការទទួលខុសត្រូវរបស់អតិថិជន

៤.១ លោក-លោកស្រី ជាម្ចាស់ប័ណ្ណ ត្រូវទទួលខុសត្រូវរាល់ប្រតិបត្តិការដែលកើតឡើងពីការប្រើប្រាស់ប័ណ្ណ (ព័ត៌មានប័ណ្ណ) ជាពិសេសប្រតិបត្តិការតាមប្រព័ន្ធអ៊ីនធឺណិត ទោះជាមានការអនុញ្ញាត ឬគ្មានការអនុញ្ញាតពីម្ចាស់ប័ណ្ណក៏ដោយ។

៤.២ លោក-លោកស្រី ជាម្ចាស់ប័ណ្ណដើម ត្រូវទទួលខុសត្រូវទាំងស្រុងនូវរាល់ការចំណាយ និងថ្លៃសេវាផ្សេងៗ រួមទាំងការមិនគោរពតាមលក្ខខណ្ឌផ្សេងៗ លើការប្រើប្រាស់ប័ណ្ណរបស់ម្ចាស់ប័ណ្ណបន្ទំផងដែរ។ ដោយប័ណ្ណដើម និងប័ណ្ណបន្ទំ មានការកំណត់ទំហំប្រតិបត្តិការប្រចាំថ្ងៃដូចគ្នា ដូច្នេះម្ចាស់ប័ណ្ណដើមត្រូវទទួលខុសត្រូវនូវរាល់ប្រតិបត្តិការដែលកើតឡើងពាក់ព័ន្ធនឹងប័ណ្ណដើម និងប័ណ្ណបន្ទំទាំងអស់ រួមទាំងការជូនដំណឹង ឬស្នើសុំមកធនាគារ ដើម្បីធ្វើមោឃភាពប័ណ្ណទាំងនោះ។

៤.៣ ព័ត៌មានប័ណ្ណ ដូចជា លេខប័ណ្ណ កាលបរិច្ឆេទផុតកំណត់ លេខសុវត្ថិភាព (លេខបីខ្ទង់ខាងក្រោយប័ណ្ណ) និងលេខសម្ងាត់ ត្រូវរក្សាឱ្យបានគង់វង្ស និងមិនត្រូវឱ្យភាគីទីបីដឹងឡើយ ទោះជាដោយចេតនា ឬអចេតនាក្តី។ ម្ចាស់ប័ណ្ណដើម ឬប័ណ្ណបន្ទំ មិនត្រូវសរសេរ ឬកត់ត្រាលេខសម្ងាត់ នៅកន្លែងណាមួយដែលអាចឱ្យភាគីទីបីដឹងឡើយ។ លោក-លោកស្រី ត្រូវទទួលខុសត្រូវចំពោះរាល់ប្រតិបត្តិការដកប្រាក់ ឬប្រតិបត្តិការផ្សេងៗរបស់ប័ណ្ណដែលគ្មានការអនុញ្ញាត បណ្តាលមកពីការធ្វេសប្រហែសរបស់លោក-លោកស្រីក្នុងការទុកដាក់ ឬប្រើប្រាស់ប័ណ្ណ ហើយមិនបានបង្កក ឬបង្ខាំងប័ណ្ណនោះទាន់ពេលវេលា។

៤.៤ ករណីបាត់បង់ ឬចោរលួចប័ណ្ណ លោក-លោកស្រី ត្រូវរាយការណ៍ជាបន្ទាន់ មកកាន់ការិយាល័យទំនាក់ទំនងអតិថិជន (៨៥៥) ២៣ ៩៩៤ ៤៤៤/១៥ ៩៩៩ ២៣៣ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកធនាគារឱ្យបានឆាប់បំផុត ឬលោក-លោកស្រី អាចធ្វើការបង្កក ឬបង្ខាំងប័ណ្ណដោយខ្លួនឯងតាមអេស៊ីលីដាម៉ូបាលស៊ូភើអេប 24/7។ លោក-លោកស្រី ត្រូវទទួលខុសត្រូវទាំងស្រុង រាល់ប្រតិបត្តិការដែលកើតឡើងពីការប្រើប្រាស់ប័ណ្ណ ក្នុងអំឡុងពេលជូនដំណឹងនេះ។ បន្ទាប់ពីទទួលបានសំណើសុំឱ្យដោះស្រាយបញ្ហាអ្វីមួយ ធនាគារនឹងធ្វើការជូនដំណឹងទៅលោក-លោកស្រី ក្នុងរង្វង់ ០៣ថ្ងៃ នៃថ្ងៃធ្វើការ ចំពោះបញ្ហាដែលមិនអាចឆ្លើយតបភ្លាមៗបាន។

## ៥ លេខសម្ងាត់ និងលក្ខខណ្ឌសុវត្ថិភាព

៥.១ ត្រូវជ្រើសរើសលេខសម្ងាត់ផ្ទាល់ខ្លួន (PIN) ដែលមាន ៦ខ្ទង់ ជាលេខទាំងអស់។

៥.២ ការជ្រើសរើសលេខសម្ងាត់ ត្រូវអនុវត្តដូចខាងក្រោម ៖

- មិនត្រូវជ្រើសរើសលេខលំដាប់ឡើង ឬលេខលំដាប់ចុះ ដូចជា ១២៣៤៥៦ ឬ ៩៨៧៦៥៤។
- មិនត្រូវជ្រើសរើសលេខដូចៗគ្នាលើសពី ៣ដង ដូចជា ៩៩៩៩៩៩។
- មិនត្រូវជ្រើសរើសលេខទូរសព្ទដៃរបស់ខ្លួនឯង។
- មិនត្រូវជ្រើសរើសលេខថ្ងៃខែឆ្នាំកំណើត ឬលេខថ្ងៃខែឆ្នាំកំណើតរបស់សមាជិកគ្រួសារ និងលេខផ្សេងទៀតដែលគេដឹងជាទូទៅនោះធ្វើជាលេខសម្ងាត់ផ្ទាល់ខ្លួនឡើយ។
- មិនត្រូវជ្រើសរើសលេខសម្ងាត់ដែលសាធារណជនទូទៅស្គាល់ និងងាយស្រួលទាយធ្វើជាលេខសម្ងាត់ឡើយ។

៥.៣ លេខសម្ងាត់ដំបូងនឹងផ្ញើចូលប្រអប់សារទូរសព្ទរបស់ម្ចាស់គណនី នៅពេលចូលដំណើរការប័ណ្ណ (Activate card) តាមម៉ាស៊ីនអេធីអឹមអេស៊ីលីដា។ លោក-លោកស្រី ត្រូវធ្វើការប្តូរភ្លាមៗនូវលេខសម្ងាត់ដែលទទួលបានពីធនាគារ តាមម៉ាស៊ីនអេធីអឹមអេស៊ីលីដា មកជាលេខសម្ងាត់ថ្មី ដែលមានចំនួន ៦ខ្ទង់ បន្ទាប់ពីចូលដំណើរការរួចរាល់។

៥.៤ មិនត្រូវអនុញ្ញាតឱ្យនរណាម្នាក់ប្រើប័ណ្ណ ឬលេខសម្ងាត់របស់លោក-លោកស្រីឡើយ។

៥.៥ មិនត្រូវឱ្យអ្នកដទៃមើលឃើញលេខសម្ងាត់ នៅពេលកំពុងធ្វើប្រតិបត្តិការឡើយ ករណីសង្ស័យថាមានគេដឹង ត្រូវប្តូរលេខសម្ងាត់នោះភ្លាម។

៥.៦ ត្រូវបញ្ចូលលេខសម្ងាត់ឱ្យបានត្រឹមត្រូវ។

៥.៧ ការបញ្ចូលលេខសម្ងាត់ មិនត្រឹមត្រូវចំនួន ៣ដង នឹងត្រូវច្រានចេញពីប្រព័ន្ធ។

៥.៨ ព័ត៌មានប័ណ្ណជាការសម្ងាត់ផ្ទាល់ខ្លួនដូចជា លេខប័ណ្ណ លេខសម្ងាត់ និងលេខសុវត្ថិភាពជាដើម។ ដូច្នេះសូមលោក-លោកស្រីជ្រាបថា មិនមានបុគ្គលិកណាម្នាក់របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ត្រូវទំនាក់ទំនងទៅកាន់លោក-លោកស្រី ក្នុងការស្នើសុំព័ត៌មានសម្ងាត់ទាំងនោះឡើយ។

៥.៩ លោក-លោកស្រី មិនត្រូវបង្ហាញព័ត៌មានប័ណ្ណដល់អ្នកណាម្នាក់ឡើយ លើកលែងតែការធ្វើប្រតិបត្តិការតាមប្រព័ន្ធអនឡាញ (Online Shopping/Internet) លោក-លោកស្រី ត្រូវប្រើប្រាស់ព័ត៌មានប័ណ្ណ ដូចជា លេខប័ណ្ណ, ថ្ងៃខែឆ្នាំផុតកំណត់, លេខកូដសុវត្ថិភាព (CSC/CVV2) និង/ឬលេខកូដផ្ទៀងផ្ទាត់ (3Ds/OTP) ដែលយកពីក្នុងប្រអប់សារទូរសព្ទរបស់លោក-លោកស្រី ឬបង្កើតដោយឧបករណ៍ Hard/Soft Token។

៥.១០ ចំពោះការប្រើប្រាស់ប័ណ្ណអេស៊ីលីដាគ្រប់ប្រភេទក្នុងការទូទាត់ផ្សេងៗ លោក-លោកស្រី ត្រូវអនុវត្តតាមការកំណត់ ដូចខាងក្រោម៖

- មិនត្រូវឱ្យគេដឹង ឬប្រាប់ ឬមើលឃើញព័ត៌មានប័ណ្ណនៅពេលប្រើប្រាស់ឡើយ។ រាល់ពេលបញ្ចូលព័ត៌មានប័ណ្ណតាមសេវាអ៊ីខុមមើស ឬទូទាត់តាមអនឡាញ ត្រូវប្រាកដថាគ្មានអ្នកណាលួចមើល។
- លោក-លោកស្រីត្រូវយល់ដឹង និងអានព័ត៌មាន Website/App ដែលត្រូវធ្វើប្រតិបត្តិការជាមួយនោះឱ្យបានច្បាស់លាស់ មុននឹងសម្រេចចិត្តបញ្ចូលព័ត៌មានប័ណ្ណអេស៊ីលីដា។
- លោក-លោកស្រីមិនត្រូវធ្វើប្រតិបត្តិការជាមួយ Website/App ដែលមិនស្គាល់ ឬមិនអាចទុកចិត្តបាន ដើម្បីបញ្ចៀសហានិភ័យផ្សេងៗដែលអាចកើតឡើង។ បើមិនដូច្នោះទេ លោក-លោកស្រី អាចប្រឈមនឹងការបាត់បង់ប្រាក់ ហើយជាការទទួលខុសត្រូវរបស់លោក-លោកស្រីផ្ទាល់។
- លោក-លោកស្រីមិនត្រូវបញ្ចូលព័ត៌មាន ឬឆ្លើយតបសំណួរអ៊ីម៉ែល ឬចម្ងល់ណាមួយជាដាច់ខាត ដើម្បីឱ្យបញ្ចូល និងបញ្ជាក់ព័ត៌មាន ឬ User Name និង Password លុះត្រាតែធ្លាប់បានទាក់ទង ឬជឿជាក់ច្បាស់អំពីប្រភពដើមនោះ។
- នៅពេលទូទាត់ តាមរយៈប្រព័ន្ធអនឡាញ នឹងមានលេខកូដផ្ទៀងផ្ទាត់ (3D Secure Code/OTP) ដែលមានចំនួន ៦ខ្ទង់ ផ្ញើតាម SMS ឬ Soft token ឬ Hard token សម្រាប់ឱ្យលោក-លោកស្រីធ្វើការបញ្ជាក់លើប្រតិបត្តិការបញ្ជាទិញ ឬទូទាត់ថ្លៃទំនិញ-សេវាកម្ម។
- ប្រសិនបើមានការសង្ស័យ ឬបានដឹងថាព័ត៌មានប័ណ្ណរបស់លោក-លោកស្រី ត្រូវបានគេដឹង ឬលួច លោក-លោកស្រីត្រូវធ្វើការបង្ខាំងប័ណ្ណដោយខ្លួនឯង តាមរយៈម៉ឺនុយបង្ខាំងប័ណ្ណ (Block Card) នៃអេស៊ីលីដាម៉ូបាលស៊ូភើរអេប ផ្ទាល់ខ្លួន ឬជូនដំណឹងមកធនាគារជាបន្ទាន់ ដើម្បីបង្ខាំង ឬចាត់វិធានការតាមលក្ខណៈបច្ចេកទេស ទប់ស្កាត់ការបន្តធ្វើប្រតិបត្តិការ។ បើការជូនដំណឹងធ្វើឡើងតាមរយៈទូរសព្ទ ត្រូវបញ្ជាក់បន្ថែមជាលាយលក្ខណ៍អក្សរ នៅការិយាល័យធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលនៅជិតបំផុត ក្នុងរយៈពេល ០២ (ពីរ) ថ្ងៃ នៃថ្ងៃធ្វើការរបស់ធនាគារ។

## ៦ ការដកប្រាក់ ឬទូទាត់ផ្សេងៗ

៦.១ នៅពេលដកប្រាក់ ឬទូទាត់ លោក-លោកស្រី ត្រូវធ្វើការផ្ទៀងផ្ទាត់សាច់ប្រាក់ ឱ្យបានត្រឹមត្រូវ មុននឹងចាកចេញពីម៉ាស៊ីន ឬបន្ទាប់ពីការធ្វើប្រតិបត្តិការតាម Online រួចភ្លាម។

៦.២ ការដកប្រាក់ ឬទូទាត់ ជារូបិយប័ណ្ណផ្សេងពីរូបិយប័ណ្ណនៃគណនី ត្រូវអនុលោមតាមអត្រាប្តូរប្រាក់ដែលកំណត់ដោយធនាគារ ឬស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ វីសា/ម៉ាស្ទ័រកាត/ចេស៊ីប៊ី/យូភីអាយ។

## ៧ ការដាក់ប្រាក់

៧.១ លោក-លោកស្រី អាចដាក់ប្រាក់ចូលគណនីដែលមាននៅធនាគារ តាមម៉ាស៊ីនអេធីអឹមអេស៊ីលីដា (CRM) ដោយប្រើប្រាស់អាយប៉េង (i-bank PayBand) ឬប័ណ្ណឥណពន្ធអេស៊ីលីដាគ្រប់ប្រភេទ ដូចជា ប័ណ្ណឥណពន្ធអេស៊ីលីដាធម្មតា/មាស, ប័ណ្ណឥណទានប្រើប្រាស់ផ្ទាល់ខ្លួន, ប័ណ្ណឥណពន្ធទូទាត់រួមស្លាកសញ្ញា និងប័ណ្ណឥណពន្ធវីសាអេស៊ីលីដា/ម៉ាស្ទ័រកាតអេស៊ីលីដា/ចេស៊ីប៊ីអេស៊ីលីដា/យូភីអាយអេស៊ីលីដា។

៧.២ លោក-លោកស្រី ត្រូវដាក់ប្រាក់ជារូបិយវត្ថុរៀល ឬរូបិយប័ណ្ណដុល្លារអាមេរិក តែប៉ុណ្ណោះ។ ចំពោះប័ណ្ណឥណពន្ធដែលភ្ជាប់ទៅនឹងគណនីប្រភពជាប្រាក់បាត ប្រព័ន្ធនឹងប្តូរប្រាក់ទៅជាប្រាក់បាត ដោយស្វ័យប្រវត្តិ យោងតាមអត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារនៅពេលដាក់ប្រាក់នោះ។

៧.៣ លោក-លោកស្រី ត្រូវធានាលើគុណភាពនៃប្រភេទក្រដាសប្រាក់ ដោយមិនត្រូវដាក់ប្រាក់ ដូចជា ប្រឡាក់, សើម, ទក់, ខ្ទេច, មូរ, ចាស់, ដាច់រហែក ឬប្រហោង, បិទស្កុត ឬមិនអាចចរាចរបាន ដូចជា ខូចខ្សែ 3D ឬ រូបដួង/លេខ 100 ធ្វើចលនាតិចតួច ឬមិនធ្វើចលនា (ចំពោះក្រដាសប្រាក់ដុល្លារអាមេរិក) នៅតាមម៉ាស៊ីន CRM ឡើយ។ ធនាគារមិនទទួលខុសត្រូវចំពោះការខូចខាត ឬភាពមិនត្រឹមត្រូវណាមួយ បណ្ដាលមកពីការអនុវត្តមិនត្រឹមត្រូវតាមលក្ខខណ្ឌនេះឡើយ។

៧.៤ លោក-លោកស្រី ត្រូវរាប់ ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់សាច់ប្រាក់ឱ្យបានត្រឹមត្រូវ និងគ្រប់ចំនួនជាមុនសិន បន្ទាប់មកត្រូវតម្រៀបក្រដាសប្រាក់តាមលំដាប់លំដោយ ឬញែកក្រដាសប្រាក់ ដែលមានប្រភេទផ្សេងគ្នា ដូចជាក្រដាស USD១០; ក្រដាស USD២០; ក្រដាស USD៥០ និងក្រដាស USD១០០ ឬក្រដាស KHR១០,០០០; ក្រដាស KHR២០,០០០; ក្រដាស KHR៥០,០០០ និងក្រដាស KHR១០០,០០០ មុននឹងដាក់ប្រាក់ទាំងនោះ តាមម៉ាស៊ីន CRM។

៧.៥ លោក-លោកស្រី មិនត្រូវធ្វើប្រតិបត្តិការក្រដាសប្រាក់ក្លែងក្លាយ ឬក្រដាសប្រាក់ថតចម្លង ឬក្រដាសប្រាក់សែន ជាដាច់ខាត។ លោក-លោកស្រី ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់នូវប្រតិបត្តិការក្រដាសប្រាក់ក្លែងក្លាយ ឬក្រដាសប្រាក់ថតចម្លង ឬក្រដាសប្រាក់សែន ដោយឥតលក្ខខណ្ឌ ឬហេតុផលណាមួយឡើយ។

**៨ ថ្លៃសេវា ការប្រាក់ និងសោហ៊ុយចំណាយផ្សេងៗ**

៨.១ ធនាគារនឹងគិតថ្លៃសេវាប្រើប្រាស់ប្រចាំខែ/ឆ្នាំ ចាប់ពីថ្ងៃចេញប័ណ្ណតទៅ ទោះជាមានការយឺតយ៉ាវ ក្នុងការមកទទួលប័ណ្ណ ក៏ដោយ។

៨.២ ការស្នើសុំប័ណ្ណថ្មី ជំនួសប័ណ្ណចាស់ ដែលខូច, បាត់ ឬចោរលួច... អាចត្រូវបង់ថ្លៃសេវា តាមការកំណត់របស់ធនាគារ។ ចំពោះថ្លៃសេវាប្រើប្រាស់ប្រចាំខែ/ឆ្នាំ ដែលបានកាត់ពីប័ណ្ណចាស់រួចហើយ ពុំត្រូវបានកាត់កងទៅឱ្យប័ណ្ណថ្មីវិញឡើយ។

៨.៣ ធនាគាររក្សាសិទ្ធិក្នុងការកាត់ថ្លៃសេវា និងកម្ទេចប័ណ្ណ ក្នុងករណីលោក-លោកស្រី មិនមកទទួលលើសពី ៦ខែ ដោយគិតចាប់ពីថ្ងៃចេញប័ណ្ណ។

៨.៤ លោក-លោកស្រី ត្រូវរក្សាសមតុល្យគណនីឱ្យបានគ្រប់គ្រាន់ ដើម្បីធានាលើគ្រប់ប្រតិបត្តិការ និងការចំណាយថ្លៃសេវានានា ដោយផ្អែកតាមការកំណត់របស់ធនាគារ។ ក្នុងករណីដែលសមតុល្យគណនីស្មើសូន្យរយៈពេលលើសមួយឆ្នាំ ធនាគាររក្សាសិទ្ធិក្នុងការមោឃភាពប័ណ្ណ។

៨.៥ ធនាគាររក្សាសិទ្ធិជាឯកច្ឆន្ទក្នុងការកាត់កងប្រាក់ចេញពីគណនីរបស់លោក-លោកស្រី ដើម្បីទូទាត់ទឹកប្រាក់ប្រតិបត្តិការ ទូទាត់បំណុល បង់ថ្លៃសោហ៊ុយចំណាយ បង់ប្រាក់ពិន័យ និងថ្លៃសេវាផ្សេងៗទៀត ដែលលោក-លោកស្រីជំពាក់ធនាគារ ឬដើម្បីកែតម្រូវលើការទូទាត់ដែលបណ្ដាលមកពីកំហុសបច្ចេកទេសណាមួយ ដោយពុំចាំបាច់ជូនដំណឹងជាមុនទៅលោក-លោកស្រីឡើយ។ ករណីគណនីមានទឹកប្រាក់មិនគ្រប់គ្រាន់ ធនាគារ នឹងជូនដំណឹងលោក-លោកស្រី ឱ្យមកដាក់ប្រាក់បន្ថែមនៅក្នុងគណនីឱ្យបានគ្រប់គ្រាន់។

៨.៦ ថ្លៃសេវាអាចមានការប្រែប្រួលស្របតាមការកំណត់របស់ធនាគារ អេស៊ីលីដា និងស្ថាប័នដៃគូ។ ចំពោះទឹកប្រាក់នៃប្រតិបត្តិការសងត្រលប់ (Refund) លោក-លោកស្រី យល់ព្រមផ្ដល់សិទ្ធិជូនធនាគារដើម្បីកាត់កម្រៃសេវានោះ តាមគោលការណ៍របស់ស្ថាប័នអន្តរជាតិដទៃ។

៨.៧ ចំពោះអ្នកប្រើប្រាស់ប័ណ្ណឥណទាន ថ្លៃសេវា និងការប្រាក់ ត្រូវអនុវត្តទៅតាមគោលការណ៍ឥណទាន និងកិច្ចសន្យាឥណទាន រវាងអ្នកប្រើប្រាស់ និងធនាគារ។

**៩ ការដោះស្រាយជម្លោះ**

៩.១ រាល់បញ្ហាផ្សេងៗ កើតមានឡើងខុសប្រក្រតី ទាក់ទងនឹងសមតុល្យក្នុងគណនីនៃប័ណ្ណអេស៊ីលីដារបស់លោក-លោកស្រី ត្រូវជូនដំណឹងមកធនាគារឱ្យបានមុនរយៈពេល ៣០ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីប្រតិបត្តិការបានកើតឡើង។ ក្នុងករណីមិនបានជូនដំណឹងមកធនាគារទាន់ពេល ធនាគាររក្សាសិទ្ធិមិនដោះស្រាយបញ្ហាជូនឡើយ។

៩.២ ធនាគាររក្សាសិទ្ធិក្នុងការដោះស្រាយបញ្ហាជូន ដោយអនុលោមតាមគោលការណ៍អន្តរធនាគារ ឬស្ថាប័នវីសា/ម៉ាស្ទ័រកាត/ចេស៊ីប៊ី/យូភីអាយ។

៩.៣ ធនាគាររក្សាសិទ្ធិក្នុងការបង្ខាំងប័ណ្ណ ឬគណនីរបស់លោក-លោកស្រី ក្នុងករណីរកឃើញថាមានការទូទាត់ប្រតិបត្តិការខុសប្រក្រតី ឬបញ្ហាមិនប្រក្រតីកើតឡើង។

**១០ ការទូទាត់សំណង**

លោក-លោកស្រី យល់ព្រមដោយឥតលក្ខខណ្ឌ ក្នុងការទូទាត់សំណងមកធនាគារនូវរាល់ការខូចខាត បាត់បង់ ការទាមទារសំណង ឬការចំណាយផ្សេងៗដែលធនាគារទទួលរង ទាក់ទងនឹងការប្រើប្រាស់ប័ណ្ណអេស៊ីលីដា និងការអនុវត្តបំពានលើកិច្ចព្រមព្រៀងនេះ រួមទាំងការខកខានមិនបានចាត់វិធានការទប់ស្កាត់ការធ្វើប្រតិបត្តិការប័ណ្ណអេស៊ីលីដា ដោយគ្មានការអនុញ្ញាត ឬប្រតិបត្តិការក្លែងបន្លំ។

**១១ ការធ្វើមោឃភាពប័ណ្ណ**

តាមឆន្ទានុសិទ្ធិ ធនាគារអាចធ្វើការបញ្ឈប់ការប្រើប្រាស់ប័ណ្ណអេស៊ីលីដា ឬបដិសេធលើសំណើសុំប័ណ្ណថ្មីជំនួសប័ណ្ណចាស់ នៅពេលណាមួយ ដោយមិនចាំបាច់ជូនដំណឹងជាមុនដល់លោក-លោកស្រីឡើយ។

**១២ ការបង្ហាញព័ត៌មានប័ណ្ណ**

១២.១ ធនាគាររក្សាសិទ្ធិក្នុងការផ្ដល់នូវរាល់ព័ត៌មាន ដែលទាក់ទងនឹងគណនីរបស់លោក-លោកស្រី ទៅកាន់ស្ថាប័នផ្សេងៗ ក្នុងករណីចាំបាច់ (រួមទាំងអាជ្ញាធរ ឬភ្នាក់ងាររដ្ឋាភិបាល) ឬក្នុងការតភ្ជាប់ជាមួយបណ្ដាញផ្ទេរប្រាក់តាមរយៈប្រព័ន្ធអេឡិចត្រូនិក (EFT)។

១២.២ តាមឆន្ទានុសិទ្ធិ ធនាគារអាចធ្វើការបង្ហាញនូវព័ត៌មានរបស់លោក-លោកស្រី នៅពេលណាមួយបានដូចខាងក្រោម៖

- សមាជិករបស់ស្ថាប័នវីសា និង/ឬម៉ាស្ទ័រកាត។ល។
- ភាគីដែលពាក់ព័ន្ធនឹងប្រតិបត្តិការប័ណ្ណ
- មានការតម្រូវពីអាជ្ញាធរមានសមត្ថកិច្ច
- ប្រើប្រាស់ក្នុងសវនកម្ម និង
- យោងលើច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

១២.៣ ធនាគាររក្សាសិទ្ធិក្នុងការប្រើប្រាស់ព័ត៌មាននៅក្នុងពាក្យស្នើសុំប័ណ្ណ និងសម្រាប់ការស្រាវជ្រាវ ឬព័ត៌មានពីប្រភពខាងក្រៅ រួមមានរបាយការណ៍អតិថិជន សកម្មភាពផ្សព្វផ្សាយទីផ្សារធ្វើឡើងដោយធនាគារ/ក្រុមហ៊ុនបុត្រសម្ព័ន្ធ។ ធនាគារអាចប្រើប្រាស់ព័ត៌មានទាំងនេះ ដើម្បីបង្កើតបញ្ជីអតិថិជន (Mailing Lists) ប្រើប្រាស់ក្នុងគោលបំណងធ្វើយុទ្ធនាការផ្សព្វផ្សាយទីផ្សារ។

១២.៤ ករណីផ្សេងទៀត ត្រូវមានការឯកភាពពីលោក-លោកស្រី និងស្របទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

## ១៣ ការប្រើប្រាស់ និងការកំណត់ឯកជនភាពនៃព័ត៌មាន ឬទិន្នន័យបុគ្គល

១៣.១ ធនាគារអាចប្រមូល និងរក្សាទុកនូវព័ត៌មានដែលផ្តល់ដោយលោក-លោកស្រី ដូចជា ឈ្មោះជាភាសាខ្មែរ និងអក្សរឡាតាំង លេខទូរសព្ទ នាមខ្លួន នាមត្រកូល ភេទ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត លេខអត្តសញ្ញាណប័ណ្ណ កាលបរិច្ឆេទផុតកំណត់អត្តសញ្ញាណប័ណ្ណ អត្តសញ្ញាណប័ណ្ណនិយោជិត អាសយដ្ឋាន អ៊ីម៉ែល និងព័ត៌មានផ្សេងទៀត ដើម្បីចុះឈ្មោះអ្នកប្រើប្រាស់សេវាប័ណ្ណអេស៊ីលីដា។

១៣.២ ធនាគារអាចប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់លោក-លោកស្រី ក្នុងករណីណាមួយដូចខាងក្រោម៖

- នៅពេលលោក-លោកស្រី ចាប់ផ្តើមបើកដំណើរការប័ណ្ណអេស៊ីលីដា
- នៅពេលមានតម្រូវការដោយគោរពតាមលក្ខខណ្ឌច្បាប់ បទប្បញ្ញត្តិ ឬអាជ្ញាធរមានសមត្ថកិច្ច
- ផ្តល់ជូនលោក-លោកស្រី នូវផលិតផល និងសេវាកម្មរបស់ធនាគារ
- គ្រប់គ្រង និងដំណើរការនូវប្រតិបត្តិការរបស់លោក-លោកស្រី
- រក្សាទុកជាព័ត៌មានផ្ទៃក្នុង
- កែលម្អ/ផ្សព្វផ្សាយ ផលិតផល និងសេវាកម្មរបស់ធនាគារឱ្យប្រសើរឡើង

១៣.៣ ធនាគារនឹងចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់លោក-លោកស្រី ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងតម្រូវការរបស់អាជ្ញាធរមានសមត្ថកិច្ច និងចែករំលែកជាមួយតតិយជនដែលបានចុះកិច្ចព្រមព្រៀងធ្វើជាអ្នកផ្តល់សេវាកម្មជាមួយធនាគារប៉ុណ្ណោះ ដើម្បីគ្រប់គ្រង និងដំណើរការនូវប្រតិបត្តិការទូទាត់របស់លោក-លោកស្រី។

១៣.៤ ធនាគារនឹងរក្សាទុកនូវព័ត៌មានផ្ទាល់ខ្លួនរបស់លោក-លោកស្រី ដោយយោងទៅលើគោលការណ៍នៃការរក្សាទុកទិន្នន័យរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។ ធនាគារអាចរក្សាទុកនូវព័ត៌មានរបស់លោក-លោកស្រី រហូតដល់រយៈពេលកំណត់ណាមួយ ដើម្បីអនុវត្តនូវកាតព្វកិច្ចរបស់ធនាគារ ស្របតាមក្របខណ្ឌច្បាប់ ឬបទប្បញ្ញត្តិ។ នៅពេលដែលព័ត៌មានរបស់លោក-លោកស្រី លែងជាតម្រូវការចាំបាច់ ធនាគារនឹងលុបចោលភ្លាមៗជាសម្ងាត់ ប្រកបដោយសុវត្ថិភាព។

១៣.៥ ធនាគារសូមធានាថាព័ត៌មានផ្ទាល់ខ្លួនរបស់លោក-លោកស្រី ត្រូវបានរក្សាទុកតាមមធ្យោបាយដែលមានសុវត្ថិភាពខ្ពស់ និងមានទំនុកចិត្ត។ ធនាគារការពារព័ត៌មានផ្ទាល់ខ្លួនរបស់លោក-លោកស្រី ដោយអនុវត្តទៅតាមយន្តការសុវត្ថិភាពខ្ពស់ វិធានការត្រួតពិនិត្យដ៏ប្រសើរបំផុតដោយរួមបញ្ចូលទាំងបច្ចេកវិទ្យាជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់ បាន encrypted ដោយបច្ចេកវិជ្ជា cryptographic ខ្ពស់បំផុត និងស្របទៅតាមស្តង់ដារសុវត្ថិភាពឧស្សាហកម្ម ដើម្បីការពាររាល់ការចូលលុកលុយ ការប្រមូល ការប្រើប្រាស់ ការបង្ហាញ ការចម្លង ការកែប្រែ ការដកចេញ ឬហានិភ័យផ្សេងទៀត ដោយគ្មានការអនុញ្ញាត។

## ១៤ ការកែប្រែ

ធនាគារ នឹងជូនដំណឹងមុនរហូតដល់ ៣០ថ្ងៃ ទៅលោក-លោកស្រី ករណីមានការបន្ថែម, លុបចោល, ផ្លាស់ប្តូរចំណុចណាមួយនៃលក្ខខណ្ឌនេះ ថ្លៃសេវា ឬបញ្ហាផ្សេងៗ ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងការទទួលខុសត្រូវរបស់លោក-លោកស្រី តាមរយៈមធ្យោបាយណាមួយ ក្នុងចំណោមមធ្យោបាយដូចខាងក្រោម៖

- ផ្ញើសារទៅកាន់ទូរសព្ទលោក-លោកស្រី ដោយផ្ទាល់
- ផ្សព្វផ្សាយជាសាធារណៈតាមរយៈសារព័ត៌មាន
- ជូនដំណឹងនៅការិយាល័យធនាគារ ឬ
- ជូនដំណឹងតាមរយៈគេហទំព័រ (Website)។

## ១៥ លក្ខខណ្ឌផ្សេងៗ

១៥.១ លក្ខខណ្ឌនៃការប្រើប្រាស់នេះ ត្រូវអនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងធ្វើឡើងជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាចិន ប្រសិនបើចំណុចណាមួយមានអត្ថន័យខុសគ្នា នោះលក្ខខណ្ឌជាភាសាខ្មែរ ត្រូវបានទទួលយកជាផ្លូវការ។

១៥.២ លក្ខខណ្ឌនេះត្រូវបានផ្តល់ជូនតាមមធ្យោបាយអេឡិចត្រូនិកផ្សេងៗដែលអាចធ្វើទៅបាន ដើម្បីបញ្ជាក់ក្នុងការប្រើប្រាស់ប័ណ្ណអេស៊ីលីដាបានត្រឹមត្រូវ។

ខ្ញុំបានអាន និងយល់ព្រមគ្រប់លក្ខខណ្ឌដែលបានបញ្ជាក់ខាងលើនេះ។